នរោត្តម សីហនុ

នៃកម្ពុជា

ប៉េកាំង ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៥

ខ្ញុំមានកិត្តិយសសូមជូនជ្រាបនូវការពិតអំពីបញ្ហាកម្ពុជាក្រោមម្តងទៀត និងអំពីកោះត្រល់ ព្រមទាំងបន្ទាត់ប្រេវីយេ ( ligne . Brévié) . Brévié ជាឈ្មោះលោកអគ្គទេសាភិបាលបារាំងដែលត្រួតត្រាឥណ្ឌូចិនបារាំងសែស( ខ្មែរ វៀតណាម និងលាវ) ។

១- អំពីកម្ពុជាក្រោម : ខ្ញុំបានជំរាបជាច្រើនលើកហើយនូវការពិតជាប្រវត្តិសាស្ត្រអំពីបញ្ហាកម្ពុជាក្រោម ។ តែដោយនៅពេលនេះមានមារសត្រូវ នរោត្តម សីហនុ នៅក្រៅប្រទេស និងក្នុងប្រទេស បានចោទប្រកាន់ខ្ញុំថា ក្បត់ជាតិ លក់ទឹកដីឲ្យបារាំង និងវៀតណាម ខ្ញុំសូមបន្ថែមនូវសេចក្តីថ្លែងថាខ្ញុំនេះ:

កើតមកជាខ្មែរ គ្មានអ្នកណាម្នាក់ដែលមិនស្រឡាញ់ជាតិ ស្រឡាញ់កម្ពុជាក្រោម និងកោះត្រល់នោះទេ ។ ខ្ញុំមិនដែលបានចោទប្រកាន់អ្នកណាម្នាក់ ថាមិនចេះស្រឡាញ់ជាតិនោះទេ ។ ខ្ញុំសូមលើកមកជំរាបតែអំពីគ្រួសារខ្ញុំ :

-នៅសតវត្សរ៍ទី២០គ្រួសារខ្ញុំ ទទួលរងទុក្ខវេទនាដោយសារកម្ពុជាក្រោម ។ ខ្មែរកម្ពុជាក្រោមជាច្រើនបានសុំឲ្យតាខ្ញុំតស៊ូទាមទារយកកម្ពុជាក្រោមមកបញ្ចូលជាមួយកម្ពុជាលើវិញ ។ លោកមានត្រកូល នរោត្តម ហើយព្រះអង្គសុគត ដោយធ្វើអត្តឃាតចងព្រះសូរង ។ មូលហេតុនៃការធ្វើអត្តឃាត គឺបណ្តាលមកពីព្រះអង្គមានការឈឺចាប់ក្នុងហឫទ័យ និងការអៀនខ្មាស់ដោយសារការទាមទារកម្ពុជាក្រោមពីបារាំងសែសមិនទទួលបានជោគជ័យ ។ ព្រះអង្គសុខចិត្តធ្វើពលីកម្មរហូតដល់ជីវិត ។

-ខ្មែរកម្ពុជាក្រោមឡើងចុះតំណាក់ជីតាខ្ញុំផ្ទាល់ ព្រះតាម ព្រះនរោត្តម សុធារស ហើយសុំឲ្យព្រះនរោត្តម សុធារស សន្យាថានៅពេលព្រះអង្គឡើងគ្រងរាជសម្បត្តិ ព្រះអង្គត្រូវទាមទារកម្ពុជាក្រោមពីបារាំងសែសមកឲ្យកម្ពុជាលើវិញ កុំឲ្យបានទៅវៀតណាម ។ ព្រះនរោត្តម សុធារស បានសន្យាជាមួយខ្មែរកម្ពុជាក្រោមទាំងនោះថា បើបារាំងថ្វាយរាជសម្បត្តិមកព្រះអង្គ ក្រោយពីព្រះករុណាព្រះបាទស៊ីសុវត្ថិ ចូលទិវង្គត់ ព្រះអង្គនឹងទាមទារពីបារាំងឲ្យទាល់តែបានកម្ពុជាក្រោមមកភ្ជាប់ជាមួយនឹងកម្ពុជាលើវិញដូចបុរាណសម័យ ។ នៅពេលនោះបារាំងសែសពិតជាថ្វាយរាជបល្ល័ង្កមកសាខាខាង នរោត្តម វិញ បានសេចក្តីថាក្រោយព្រះបាទស៊ីសុវត្ថិ នឹងថ្វាយព្រះនរោត្តមម្នាក់ឡើងគ្រងរាជ្យសម្បត្តិ ។ បារាំងបានតាំងព្រះជាយាល័យ ព្រះនរោត្តម សុធារស ដើម្បីដាក់តាំងនៅពេលព្រះអង្គឡើងគ្រងរាជ្យ ។ ដោយខ្វល់ពេកក៏មានពិធីភ្ជាប់ងារសិងាត់ថានៅពេលព្រះអង្គឡើងសោយរាជ្យ ព្រះអង្គនឹងទាមទារកម្ពុជាក្រោមពីបារាំងភ្លាម បារាំងសែសក៏សំរេចឈប់ថ្វាយ ព្រះនរោត្តម សុធារស សោយរាជ្យ ហើយយកព្រះជាយាល័យព្រះអង្គដែលបានតាំងរួចហើយ ទៅទម្លាក់ទៅក្នុងទន្លេបួនមុខ។ ព្រះនរោត្តម សុធារស ក៏អស់រាជ្យសម្បត្តិដោយសេចក្តីស្នេហាជាតិរបស់ព្រះអង្គ ។

(...)

**២**- ចំពោះខ្ញុំ ក្រោយពីបារាំងសែសថ្វាយរាជសម្បត្តិឲ្យខ្ញុំ ខ្ញុំបានរារាំងប្រទេស ថៃ ប្រទេសវៀតណាម ដែលខ្លាំងជាងយើង កុំឲ្យមកលេបត្របាក់ ពង្រួញ ទំហំទឹកដីខ្មែរយើងតទៅទៀតបាន។ ហេតុដូច្នេះហើយ បានជាខ្ញុំសុំឲ្យ បណ្តាប្រទេសនានាទទួលស្គាល់ជាផ្លូវការនូវព្រំដែនកម្ពុជានាបច្ចុប្បន្ននេះ។ ខ្ញុំសូមបញ្ជាក់ថា នេះ មិនមែនមានន័យថា ខ្ញុំសុខចិត្តផ្ទេរកម្ពុជាក្រោម កោះត្រល់ឲ្យទៅបារាំង និងវៀតណាមទេ។

ការពិត គឺសុំគេ កុំឲ្យលេបត្របាក់ជាបន្តទៅទៀតនូវទឹកដីកម្ពុជា ដែលតូចណាស់ទៅហើយ គឺសុំឲ្យឈប់ត្រឹមហ្នឹងហើយ ត្បិតនៅពេលនោះ **ង៉ោ ឌិនយៀម** (ប្រធានាធិបតីវៀតណាមខាងត្បូង) ទាមទារយកកោះសេះ កោះអន្តតាយ និងកោះដែល នៅជិតកែបពីកម្ពុជា។

ដូច្នេះ ខ្ញុំសូមជនរួមជាតិ មេត្តាបែងចែកឲ្យច្បាស់លាស់ពី៖

**ក**. នរោត្តម សីហនុ មិនដែលទទួលស្គាល់ថា ស្របច្បាប់ និងសមហេតុ ផលអំពីកម្ពុជាក្រោម កោះត្រល់ បានទៅបារាំង ឬវៀតណាមនោះទេ។

**ខ**. យើងមិនភ្លេចភ្លាំងថាយើងខ្សោយ កងទ័ពយើងមានចំនួនតិចជាងគេ ហើយយើង ត្រូវបញ្ឈប់ប្រទេសធំៗទាំងអស់ហ្នឹងកុំឲ្យវាទទន្រ្ទានយកទឹក ដីយើងសព្វថ្ងៃនេះទៀតទេ។ យើងខ្លាចទឹកដីយើង កាន់តែរួញតូចទៅៗ។

នៅសតវត្សរ៍ទី២១នេះ ទឹកដីយើងបានបាត់បងរួចទៅហើយ។ ប្រជារាស្រ្ត ដែលធ្លាប់ តែធ្វើស្រែចម្ការ ពីដូនតាមកនៅលើទឹកដីរបស់ខ្លួន បានត្រូវវៀត ណាមប្រកាសថាជាទឹកដី របស់គេ។ លោកមេធាវី Michel BUISSON របាយការណ៍របស់ឥស្សរជននិស្សិតជាច្រើន សុទ្ធតែបានបង្ហាញនូវការបាត់បង់ទឹកដី។ ចំណែករដ្ឋអំណាចនៅតាមព្រំដែនវិញ គ្នាពុំហ៊ានធ្វើអត្ថាធិប្បាយអ្វីទេ។ ដូច្នេះ នាបច្ចុប្បន្នកាលនេះ យើងបែកបាក់គ្នាទៅហើយ រវាងអ្នកដែល និយាយថា កម្ពុជាចំណេញទឹកដី (រហូតចំណេញទឹកជូនប្រជារាស្រ្តប្រើ ប្រាស់ទៀត) និងអ្នកដែលយល់ឃើញថា ទឹកដីកម្ពុជាបានត្រូវគេលេបត្របាក់ ជាច្រើនណាស់ទៅហើយ។ ការពិត វាយ៉ាងណាទៅ?។

បច្ចុប្បន្ននេះ ខ្ញុំមិនធ្វើជាចៅក្រមកាត់សេចក្តីថា ខាងណាខុស ខាងណាត្រូវទេ។ ដោយហេតុនេះហើយ បានជាខ្ញុំមិនត្រឡប់ទៅកាន់មាតុប្រទេសវិញ។ ខ្ញុំសុំទោសផងចុះ ពីព្រោះការពិត យើងមិនទាន់ដឹងច្បាស់លាស់ នៅឡើយទេ។ ខ្ញុំសូមដកខ្លួនសិន ហើយសុំកុំឲ្យចោទថា ខ្ញុំក្បត់ជាតិ។ ខ្ញុំមិនដែលក្បត់ជាតិម្តងណាទាល់តែសោះ ក្នុងមួយជីវិតខ្ញុំនេះ។ ផ្ទុយទៅ វិញខ្ញុំមានតែការពារជាតិមិនដែលឈប់ឈរ។

កូនចៅ ចៅទួត ដែលសព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ប្រទេសបារាំង អូស្រ្តាលី ។ល។ ហើយដែលមានសេរីភាព បានផ្ញើអ៊ីមេលមកខ្ញុំ កោតសរសើរសម្តេចឪ សម្តេចតា សម្តេចតាទួត ថាខែងរែងមែន មិនដែលលះបង់ឧត្តមប្រយោជន៍ ជាតិ បូរណភាពទឹកដីទេ។ សម្តេចតា សម្តេចតាទួត ជាអ្នកស្នេហាជាតិ ដ៏បរិសុទ្ធ ចំណាស់នៅក្នុងប្រវត្តិសាស្រ្ត។

ខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ បើមានកិច្ចការអ្វី ដែលអយុត្តិធម៌ចំពោះខ្ញុំទៀត ខ្ញុំនឹងមិននៅស្ងៀមទេ គឺខ្ញុំតស៊ូជាដរាប រហូតដល់អវសាន្តនៃជីវិត។ ប៉ុន្តែខ្ញុំសូមជនរួមជាតិ មេត្តាយោគយល់ និងអភ័យទោស ដោយខ្ញុំមិនអាចចូលទៅក្នុងប្រទេសជាតិវិញ ត្បិតអយុត្តិធម៌ មាច្រើនណាស់ចំពោះ ខ្ញុំ។

ខ្ញុំនឹងធ្វើការតាម ព្រះនរោត្តម យុគន្ធរ ដែលការពារឯករាជ្យ ការពារបូរណភាពទឹកដី ហ៊ានប្រឆាំងជាមួយបារាំងសែស ហើយដែលត្រូវបារាំងសែស និរទេស ព្រះអង្គ ទៅនៅឯបរទេសរហូតដល់ព្រះអង្គសុគត។

សូមអរគុណជាអនេកប្បការ



នរោត្តម សីហនុ

*(ទំព័រទី២ នេះ សរសេរចម្លងឡើងវិញ)*